مدرسة اهل البيت

# សាលា

# អាស្ហ់លុល-បៃត៏

## សៀវភៅ ប្រវត្តិសាស្រ្ត (تَارِيْخ) ថ្នាក់ទី ២

(អាយុ ៦-៧ ឆ្នាំ)

قَالَ اَلنَّبِيُّ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ : طَلَبُ اَلْعِلْمِ فَرِيضَةٌ عَلَى كُلِّ مُسْلِمٍ وَ مُسْلِمَةٍ (بحار الأنوار ج ١ ص ١٧٧)

ព្រះសាស្តាﷺមានព្រះវចនៈថាៈ "ស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចលើមុស្លីមប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ ព្រះសាស្តាអាដាំ (عليه السلام) ........ ៥

មេរៀនទី ២ ទេវតា ........ ៨

មេរៀនទី ៣ ព្រះសាស្តាមូហាំម៉ាដ់ (صلی الله علیه وآله وسلم) ........ ១១

មេរៀនទី ៤ សៃយីដាស់ហ្វាទីម៉ាស់ (سلام الله علیها) ........ ១៤

មេរៀនទី ៥ អ៊ីម៉ាំអាលី (صلوات الله عليه والسلام) ........ ១៧

មេរៀនទី ៦ អ៊ីម៉ាំហាសាន់ (صلوات الله عليه والسلام) ........ ២០

មេរៀនទី ៧ អ៊ីម៉ាំហ៊ូសែន៍ (صلوات الله عليه والسلام) ........ ២៣

មេរៀនទី ៨ អ៊ីម៉ាំ អាលី ស៊ៃនុល-អាប៊ីឌីន (صلوات الله عليه والسلام) ........ ២៦

មេរៀនទី ៩ អ៊ីម៉ាំ មូហាំម៉ាដ់ អាល់-បាក្វៀរ (صلوات الله عليه والسلام) ........ ២៩

មេរៀនទី ១០ អ៊ីម៉ាំ យ៉ាក់ហ្វារ អាស់-ស៍ឌិក្វ (صلوات الله عليه والسلام) ........ ៣២

មេរៀនទី ១១ អ៊ីម៉ាំ មូសា អាល់-កាស៊ីម (صلوات الله عليه والسلام) ........ ៣៦

មេរៀនទី ១២ អ៊ីម៉ាំ អាលី អារ-រីដ៏ (صلوات الله عليه والسلام) ........ ៣៩

មេរៀនទី ១៣ អ៊ីម៉ាំ មូហាំម៉ាដ់ អាត់-តាគ្វី (صلوات الله عليه والسلام) ........ ៤២

មេរៀនទី ១៤ អ៊ីម៉ាំ អាលី អាន់-ណាគ្វី (صلوات الله عليه والسلام) ........ ៤៥

មេរៀនទី ១៥ អ៊ីម៉ាំ ហាសាន់ អាល់-អាស់ការី (صلوات الله عليه والسلام) ........ ៤៨

មេរៀនទី ១៦ អ៊ីម៉ាំ មូហាំម៉ាដ់ អាល់-ម៉ាស់ឌី (صلوات الله عليه والسلام) ........ ៥២

## មេរៀនទី ១

# ព្រះសាស្តាអាដាំعليه السلام

កាលពីយូរអង្វែងមកហើយ អល់ឡោះហ៍عز وجلបានបង្កើតមេឃនិងដី ។

បន្ទាប់មក អល់ឡោះហ៍عز وجلបានប្រាប់អស់ទេវតាថាព្រះអង្គعز وجلនឹងបង្កើតមនុស្សម្នាក់ ហើយព្រះអង្គعز وجلនឹងចាត់បញ្ជូនមនុស្សនោះទៅកាន់ផែនដីដើម្បីមើលថែរក្សាផែនដីនោះ ។

ព្រះអង្គعز وجلក៏បានបង្កើតមនុស្សដំបូងបង្អស់ ពោលគឺ ព្រះសាស្តាصلى الله عليه وآله وسلمអាដាំعليه السلام ដែលជាព្រះសាស្តាទីមួយរបស់យើងផងដែរ ។

អល់ឡោះហ៍عز وجلបានបង្កើតព្រះសាស្តាអាដាំعليه السلامពីដីឥដ្ឋ ។ បន្ទាប់មក អល់ឡោះហ៍عز وجلបានបង្កើតហាវ៉ាسلام الله عليهاជាគូស្រករបស់ព្រះសាស្តាអាដាំعليه السلام ។

ក្រោយពីបានបង្កើតព្រះសាស្តាអាដាំعليه السلامហើយ អល់ឡោះហ៍عز وجلបានប្រាប់ប្រជានិករទាំងអស់នៃឋានសួគ៌ឲ្យក្រាបប្រណិប័តន៍ (ស៊ូជូដ ក្រាបសំពះ) ព្រះសាស្តាអាដាំعليه السلام ។

កាលនោះសៃតនلعن اللهជាជិនល្អមួយរូប នៅឯឋានសួគ៌ដែរ ។ ទេវតាទាំងអស់បានធ្វើតាមអល់ឡោះហ៍عز وجل ហើយបានក្រាបប្រណិប័តន៍ ។ តែសៃតនلعن اللهមិនព្រមក្រាបប្រណិប័តន៍ទេ ។

សៃតនلعن اللهបានថាវាلعن اللهគ្រាន់បើជាងព្រះសាស្តាអាដាំعليه السلام ព្រោះវាلعن اللهត្រូវបង្កើតមកពីភ្លើង រីឯព្រះសាស្តាអាដាំعليه السلامត្រូវបង្កើតមកពីដី ។

អល់ឡោះហ៍عز وجلក៏បានបណ្តេញសៃតនلعن اللهចេញពីឋានសួគ៌ ព្រោះវាلعن اللهមិនព្រមធ្វើតាមបង្គាប់ព្រះអង្គعز وجل ។

ព្រះសាស្តាអាដាំعليه السلامនិងហាវ៉ាسلام الله عليهاបានរស់នៅក្នុងឋានសួគ៌ ។ ពេលព្រះអង្គعليهم السلامចង់បានអ្វីនឹងបានហ្នឹង ស្រេចតែចិត្ត ។ គេបានសូមកុំឲ្យតែព្រះអង្គទាំងពីរعليهم السلامបរិភោគផ្លែរបស់ដើមឈើមួយដើមប៉ុណ្ណោះ ។

សៃតន لعنه الله ដឹងរឿងនេះ វា لعنه الله ច្រណែនព្រះសាស្ដាអាដាំ عليه السلام និងហាវ៉ា سلام الله عليها ណាស់ព្រោះអល់ឡោះហ៍ عز وجل ស្រឡាញ់ព្រះអង្គទាំងពីរ عليهم السلام ណាស់ ។ ដូច្នេះ សៃតន لعنه الله បានបញ្ឆោតព្រះសាស្ដាអាដាំ عليه السلام និងហាវ៉ា سلام الله عليها ដោយនិយាយកុហក ដើម្បីនឹងធ្វើព្រះឲ្យអង្គទាំងពីរ عليهم السلام បរិភោគផ្លែឈើដែលគេបានហាមនោះ ។

ព្រះសាស្ដាអាដាំ عليه السلام មិនធ្លាប់បានជួបប្រទះការនិយាយកុហក កាលពីមុនមកឡើយ ហេតុដូច្នេះឯងបានជាព្រះអង្គ عليه السلام ជឿសៃតន لعنه الله ។ ក្រោយពីបានបរិភោគផ្លែឈើរួចភ្លាម ព្រះសាស្ដាអាដាំ عليه السلام និងហាវ៉ា سلام الله عليها ក៏បានភ្ញាក់ស្មារតី ដឹងខ្លួនថាបានប្រព្រឹត្តអំពើអគប្បី ។

ព្រះអង្គទាំងពីរ عليهم السلام សោកស្ដាយណាស់ ហើយបានសូមខមាទោសអល់ឡោះហ៍ عز وجل ។

អល់ឡោះហ៍ عز وجل បានលើកទោសឲ្យព្រះអង្គទាំងពីរ عليهم السلام តែព្រះអង្គ عز وجل មិនលើកទោសឲ្យសៃតន لعنه الله ទេ ។

អល់ឡោះហ៍ عز وجل បានបញ្ជូនព្រះសាស្ដាអាដាំ عليه السلام និងហាវ៉ា سلام الله عليها មកឯផែនដី ។

# លំហាត់ ១

ចូរគូសខ្វែងជើងក្អែកលើរូបនរកខាងក្រោមនេះ ដែលស្ហៃតន្ទ ﷻ នឹងចូលទៅក្នុងនោះ ។ អ្នកនឹងមិនចូលនរកទេ ព្រោះអ្នកស្តាប់អល់ឡោះហ្ទ៍ ﷻ ។



នរក

អ្នកនឹងបានចូលឋានសួគ៌ព្រោះអ្នកស្តាប់អល់ឡោះហ្ទ៍ ﷻ ។ ចូរគូរអ្វីដែលអ្នកចង់បាននៅក្នុងឋានសួគ៌ ពេលអ្នកបានចូលឋានសួគ៌ ។

## មេរៀនទី ២

# ទេវតា

ទេវតាជាសត្វលោករបស់អល់ឡោះហ៍ﷻដូចយើងដែរ ។

ទេវតាធ្វើតាមព្រះបញ្ជារបស់អល់ឡោះហ៍ﷻ មិនអាចល្មើសបង្គាប់ព្រះអង្គﷻ បានទេដូចយើងល្មើសបង្គាប់ព្រះអង្គﷻដែរនោះ ពេលស្ហៃតូន(لعنه الله)លោមបញ្ឆោតយើង ។

យើងមិនអាចមើលទេវតាឃើញទេ ដូច្នេះយើងមិនដឹងថាទេវតាដូចអ្វីទេ ។ យើងគ្រាន់តែដឹងថាទេវតាមានស្លាប ។

មានច្រើនមូលហេតុដែលទេវតាត្រូវបង្កើតមកនោះ ។ ទេវតាខ្លះមិនធ្វើអ្វីផ្សេងទេក្រៅពីគោរពសក្ការៈអល់ឡោះហ៍ﷻតែម្យ៉ាង ។ ទេវតាឯទៀតមានភារកិច្ចជាច់មុខដូចជានាំព្រះរាជសាររបស់អល់ឡោះហ៍ﷻមកឲ្យព្រះសាស្ដា(عليهم السلام)ជាដើម ។ ទេវតាដទៃទៀតមានភារកិច្ចមើលថែរក្សាយើង ។

យើងម្នាក់ៗមានទេវតាពីរដែលតាមយើងជាប់គ្រប់ពេល នៅលើស្មានីមួយៗ ។ ទេវតានៅលើស្មាស្ដាំកត់ទុកនូវអំពើល្អទាំងអស់ដែលយើងធ្វើ ទេវតានៅលើស្មាឆ្វេងកត់ទុកនូវអំពើអាក្រក់ទាំងអស់ដែលយើងធ្វើ ។

ទេវតាបួនអង្គដែលគេស្គាល់ជាងគេគឺៈ

១) យ៉ីបរ៉អ៊ីល(عليه السلام) ។ ព្រះអង្គ(عليه السلام)មានភារកិច្ចនាំព្រះរាជសាររបស់អល់ឡោះហ៍ﷻមកឲ្យព្រះសាស្ដា(عليهم السلام) ។ ព្រះអង្គ(عليه السلام)នាំអាយ៉ាស់គួរអានមកឲ្យព្រះសាស្ដាមូហាំម៉ាដ់ﷺ ។

២) មីកាអ៊ីល(عليه السلام) ។ ព្រះអង្គ(عليه السلام)ផ្ដល់រីស្គី (رِزْق គ្រឿងទ្រទ្រង់ជីវិត) ចាំបាច់ឲ្យយើង គឺៈ ខ្យល់ ទឹក គ្រឿងបរិភោគ សំលៀកបំពាក់ ។

៣) អ៊ីស្ររ៉អ៊ីល (عِزْرَائِيل) (عليه السلام) ។ ទេវតាយមទូត (គឺទេវតាយកព្រលឹង) ។ ព្រះអង្គ(عليه السلام)នាំយើងត្រឡប់ទៅឯអល់ឡោះហ៍ﷻ ។

៤) អ៊ីសរ៉ហ្វីល عَلَيْهِ السَّلَام ។ ព្រះអង្គ عَلَيْهِ السَّلَام នឹងផ្លុំត្រែក្នុងថ្ងៃដែលធ្វើឲ្យសព្វសារពើស្លាប់ ហើយព្រះអង្គ عَلَيْهِ السَّلَام នឹងផ្លុំត្រែម្តងទៀតដើម្បីនឹងធ្វើឲ្យទាំងអស់គ្នារស់វិញ ក្នុងថ្ងៃជំនុំជម្រះ ។

# លំហាត់ ២

ចូរនិយាយប្រាប់ឪពុកម្ដាយឲ្យដឹងអំពីទេវតា ។ ចូរផាត់ពណ៌រូបទេវតាខាងក្រោមនេះ ។



ចូរគូររូបទេវតានៅលើស្មាទាំងពីររបស់អ្នក ។ តើទេវតាមួយណាកត់ត្រាច្រើនជាងគេ ?





**មេរៀនទី ៣**

# ព្រះសាស្ដាមូហាំម៉ាដ់ﷺ

ថ្ងៃមួយ ព្រះសាស្ដាមូហាំម៉ាដ់ﷺបានធ្វើដំណើរ ។ ព្រះអង្គﷺអស់កម្លាំងពេកក៏បានឈប់សម្រាកក្រោមដើមឈើមួយដើម ។

បុរសកំណាចម្នាក់ឃើញព្រះអង្គﷺម្នាក់ឯង ក៏គិតថានេះជាឱកាសល្អដើម្បីសម្លាប់ព្រះអង្គﷺដោយស្ងាត់ៗយ៉ាងរហ័ស ។ គាត់ដើរសំដៅទៅរកព្រះអង្គﷺដោយហូតដាវ ។

បុរសកំណាចបានសួរព្រះសាស្ដាﷺថា៖ "អ្នកណានឹងជួយឯងﷺ ?" ព្រះសាស្ដាﷺបានឆ្លើយយ៉ាងស្ងៀមថា៖ "អល់ឡោះហ៍ﷻ ។"

ពេលបុរសកំណាចឃើញព្រះសាស្ដាﷺរក្សាអាការស្ងៀមស្ងាត់ មានអាការនឹងធឹង មិនតក់ស្លុតទេ គាត់ក៏ភ័យតក្កមា ធ្លាក់ដាវពីដៃ ។

ព្រះសាស្ដាមូហាំម៉ាដ់ﷺរើសដាវ ហើយសួរគាត់ថា៖ "ពេលនេះប្រាប់ខ្ញុំﷺមក អ្នកណានឹងជួយលោក ?" បុរសនោះតបថា៖ "មិនមានអ្នកណាជួយខ្ញុំទេ ។"

ព្រះសាស្ដាﷺក៏មានព្រះវចនៈថា៖ "មិនពិតទេ ! អល់ឡោះហ៍ﷻនឹងជួយលោកដែរ ។" ព្រះស្ដាﷺក៏បានលែងបុរសនោះ មិនរករឿងគាត់ទេ ។

លុះបានឮដូច្នេះ បុរសនោះក៏បានទៅជាមុស្លីម ។

**លំហាត់ ៣**ក

# ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلم

ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلمប្រសូតនៅឯ ម៉ាក់កាស់, ថ្ងៃសុក្រ ទី ១៧ ខែ រ៉ប៊ីអ៊ុល អាវ៉ាល់ ឆ្នាំដំរី (عَامُ الْفِيلِ) ត្រូវនឹងឆ្នាំ ៥៧០ នៃគ្រិស្តសករាជ ។ ព្រះអង្គصلى الله عليه وآله وسلمសោយ ព្រះទិវង្គតនៅឯម៉ាឌីណាស់ ថ្ងៃទី ២៨ ខែ ស្វ៉ហ្វារ ឆ្នាំ ១១ សករាជហ៊ីជ្រ៉ោះត៍ (គឺ ក្រោយពីបានភៀសខ្លួនទៅកាន់ម៉ាឌីណាស់) ត្រូវនឹងឆ្នាំ ៦៣២ នៃគ្រិស្តសករាជ ។



**លំហាត់ ៣ខ**

ចូរនិយាយរឿងព្រះសាស្ដាមូហ្ាំម៉ាដ់ﷺ និងបុរសកំណាចឲ្យឪពុកម្ដាយអ្នកស្ដាប់ ។ ចូរផាត់ពណ៌រូប ។



ឧត្តមគតិរឿងនេះគឺ អល់ឡោះហ៊្ុعزوجلជួយអ្នកជានិច្ច ទោះបីអ្នកកាចក៏ដោយ ព្រោះព្រះអង្គعزوجلស្រឡាញ់ទាំងអស់គ្នា ។ ដើម្បីអរព្រះគុណអល់ឡោះហ៊្ុعزوجلយើងត្រូវព្យាយាមប្រព្រឹត្តខ្លួនជាមុស្លីមល្អ ។

## មេរៀនទី ៤

# សៃយីដាស់ហ្វាទីម៉ាស់سلام الله عليها

ថ្ងៃមួយ បុរសចំណាស់ម្នាក់បានមកឯផ្ទះសៃយីដាស់ហ្វាទីម៉ាស់سلام الله عليهاដើម្បីសូមជំនួយពីព្រះនាងسلام الله عليها ។

សៃយីដាស់ហ្វាទីម៉ាស់سلام الله عليهاពុំមានអ្វីឲ្យទៅបុរសចំណាស់ទេ ក្រៅពីខ្សែកមួយខ្សែដែលបងប្អូនជីដូនមួយព្រះនាងسلام الله عليهاឲ្យព្រះនាងسلام الله عليها ។ ព្រះនាងسلام الله عليهاក៏បានដោះខ្សែកនោះឲ្យទៅបុរសចំណាស់ ដោយប្រាប់គាត់ឲ្យយកវាទៅលក់យកប្រាក់មកចាយវាយ ។

បុរសម្នាក់ឈ្មោះ អាំម៉ារ ដែលជាមិត្តរបស់ព្រះសាស្តាصلى الله عليه وآله وسلمបានទិញខ្សែកនោះពីបុរសចំណាស់ដោយឲ្យគាត់គ្រឿងបរិភោគ សំលៀកបំពាក់ សេះមួយនិងប្រាក់ខ្លះ ។

បន្ទាប់ពីនោះ អាំម៉ារ បានចាត់បញ្ជូនបាវបម្រើម្នាក់របស់លោកទៅជួបព្រះសាស្តាصلى الله عليه وآله وسلم ប្រាប់បាវបម្រើនោះថាឲ្យប្រាប់ព្រះសាស្តាصلى الله عليه وآله وسلمថាលោកសូមជូនព្រះអង្គصلى الله عليه وآله وسلمខ្សែកនិងបាវបម្រើម្នាក់ជាអំណោយ ។

ពេលព្រះសាស្តាصلى الله عليه وآله وسلمបានជ្រាប ព្រះអង្គصلى الله عليه وآله وسلمបានឲ្យបាវបម្រើនិងខ្សែកទៅសៃយីដាស់ហ្វាទីម៉ាស់سلام الله عليهاជាអំណោយ ។ សៃយីដាស់ហ្វាទីម៉ាស់سلام الله عليهاបានអរគុណបាវបម្រើនោះដែលបានយកខ្សែកមកឲ្យព្រះនាងسلام الله عليهاវិញ ហើយព្រះនាងسلام الله عليهاបានដោះលែងបាវបម្រើនោះឲ្យមានសេរីភាព ។

ខ្សែកអស្ចារ្យមែន ! វាបានផ្តល់គ្រឿងបរិភោគ សំលៀកបំពាក់ សេះ ប្រាក់ បានដោះលែងបុរសម្នាក់ឲ្យមានសេរីភាព នៅទីបំផុតវាវិលប្រឡប់រកម្ចាស់វាវិញ ។

ឧត្តមគតិរឿងនេះគឺ អ្នកគប្បីបរិច្ចាគរបស់ដែលអ្នកមានឲ្យទៅមនុស្សដែលកំពុងតែត្រូវការជាចាំបាច់របស់នោះ ។ អល់ឡោះហ្វ៍عزّ وجلّនឹងប្រទានឲ្យអ្នកវិញច្រើនលើសនោះ ។

## លំហាត់ ៤ក

ព្រះនាង ហ្វាទីម៉ាស្ទ់ អាស្ស៊ស្ហាស្វ់រ៉អ៊ុ سلام الله عليها ប្រសូតនៅឯម៉ាក់កាស្ទ់ ថ្ងៃសុក្រទី ២០ ខែ យ្ហ៊ូម៉ាដា អាល់-អាឃ្ហ៊ីរ៉ោះត៌ (جُمَادَى الآخِرَة) ៨ ឆ្នាំមុនសករាជហ្ជ៊ីច្រ៉ោះត៌ ត្រូវនឹងឆ្នាំ ៦១៥ នៃគ្រិស្តសករាជ ។ ព្រះនាងសោយទិវង្គតនៅម៉ាឌីណាស្ទ់ ថ្ងៃទី ៣ ខែ យ្ហ៊ូម៉ាដា អាល់-អាឃ្ហ៊ីរ៉ោះត៌ ឆ្នាំ ១១ សករាជហ្ជ៊ីច្រ៉ោះត៌ ត្រូវនឹងឆ្នាំ ៦៣២ នៃគ្រិស្តសករាជ ។



## លំហាត់ ៤ខ

ចូរនិយាយរឿងសៃយីដ្ហាស់ហ្វាទ្ធីម៉ាស់ ﷽سلام الله عليها ឲ្យឪពុកម្ដាយអ្នកស្ដាប់ ។ ចូរស្មានមើលថាតើខ្សែកនោះដូចអ្វី ហើយចូរគូលើខ្សែខាងក្រោមនេះដើម្បីឲ្យវាដូចខ្សែកដែលអ្នកស្មាននោះ ។



## មេរៀនទី ៥

# អ៊ីម៉ាំអាលី صلوات الله عليه والسلام

ថ្ងៃមួយអ៊ីម៉ាំទី ១ របស់យើង គឺអ៊ីម៉ាំអាលី صلوات الله عليه والسلام បានទៅផ្សារជាមួយបម្រើព្រះអង្គ صلوات الله عليه والسلام ឈ្មោះកួន់បារ (قَنْبَرُ) ។ ព្រះអង្គ صلوات الله عليه والسلام បានទិញអាវពីរ ។ អាវមួយល្អនិងថ្លៃណាស់ ឯអាវមួយទៀតមិនសូវល្អទេ ។

ពេលត្រឡប់មកផ្ទះវិញ អ៊ីម៉ាំអាលី صلوات الله عليه والسلام ឲ្យអាវល្អទៅកួន់បារ ទុកអាវមួយទៀតសម្រាប់ខ្លួនឯង ។

កួន់បារបានប្រាប់អ៊ីម៉ាំអាលី صلوات الله عليه والسلام ថា យកល្អព្រះអង្គ صلوات الله عليه والسلام ត្រូវពាក់អាវល្អព្រោះព្រះអង្គ صلوات الله عليه والسلام ជាអគ្គប្រមុខរបស់មុស្លីម ឯខ្លួនគាត់គ្រាន់តែជាបាវបម្រើម្នាក់ប៉ុណ្ណោះ ។

អ៊ីម៉ាំអាលី صلوات الله عليه والسلام បានឆ្លើយកួន់បារថាគាត់ទេដែលត្រូវពាក់អាវល្អនោះ ព្រោះគាត់ក្មេងជាង អាវនោះស័ក្តិសមនឹងគាត់ជាង ។ សំខាន់លើសនោះគឺអ៊ីម៉ាំ صلوات الله عليه والسلام បានប្រាប់កួន់បារថាព្រោះតែព្រះអង្គ صلوات الله عليه والسلام ជាមេដឹកនាំមុស្លីម បានជាព្រះអង្គ صلوات الله عليه والسلام ត្រូវបង្ហាញគំរូល្អដោយមានជីវិតរស់នៅសាមញ្ញ ។

ឧត្តគតិរឿងនេះគឺ៖

១) ចូរបរិច្ចាគអ្វីដែលល្អ ។

២) ចូរគាប់ចិត្តនឹងរបស់របរសាមញ្ញ ចូរកុំចង់បានច្រើនពេក ។

## លំហាត់ ៥ក

# អ៊ីម៉ាំអាលី صلوات الله عليه والسلام

អ៊ីម៉ាំអាលី صلوات الله عليه والسلام ប្រសូតនៅឯមាក់កាស្ហ ថ្ងៃទី ១៣ ខែ រ៉យ៉ាប់ ២៣ ឆ្នាំមុនសករាជហ៊ីជ្រ៉ោះត៍ ត្រូវនឹងថ្ងៃទី ២៥/០៥/៦០០ នៃគ្រិស្តសករាជ ។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គតនៅគូហ្វាស្ហ ថ្ងៃទី ២១ ខែ រ៉ម៉ាដូន ឆ្នាំ ៤០ សករាជហ៊ីជ្រ៉ោះត៍ ត្រូវនឹងថ្ងៃទី ២៧/០១/៦៦១ នៃគ្រិស្តសករាជ ។



# លំហាត់ ៥២

អាវមួយណាស្អាតជាងគេ ។ តើអ្នកដឹងទេថាអ៊ីមុាំទីមួយរបស់យើង អ៊ីមុាំអាលី صلوات الله عليه والسلام ឲ្យបម្រើព្រះអង្គ صلوات الله عليه والسلام អាវមួយណា ?





ចូរគូររបស់ល្អមួយដែលអ្នកមាន ដែលអ្នកអាចបរិច្ចាគឲ្យទៅអ្នកក្រ ។









## មេរៀនទី ៦

# អ៊ីម៉ាំហ្សាសាន់ صلوات الله عليه والسلام

អ៊ីម៉ាំទី ២ របស់យើង គឺអ៊ីម៉ាំ ហ្សាសាន់ صلوات الله عليه والسلام មានមេត្តាដល់ជនក្រីក្រណាស់ ។

ថ្ងៃមួយ អ៊ីម៉ាំហ្សាសាន់ صلوات الله عليه والسلام កំពុងដើរតាមផ្លូវ ព្រះអង្គ صلوات الله عليه والسلام ប្រទះជនក្រីក្រអង្គុយផ្ទាប់ដីហូបអាហារក្រៀមក្រោះ ។ ពេលឃើញអ៊ីម៉ាំហ្សាសាន់ صلوات الله عليه والسلام ពួកគេហៅព្រះអង្គ صلوات الله عليه والسلام បរិភោគដែរ ។ អ៊ីម៉ាំ صلوات الله عليه والسلام អង្គុយផ្ទាប់ដីបរិភោគអាហារក្រៀមក្រោះជាមួយជនក្រីក្រទាំងនោះ ។

លុះបរិភោគរួច អ៊ីម៉ាំ صلوات الله عليه والسلام ងើបឡើងដើម្បីចាកចេញ តែមុននឹងចាកចេញទៅ ព្រះអង្គ صلوات الله عليه والسلام បានអរគុណជនក្រីក្រទាំងនោះ ដែលបានចែករំលែកអាហាររបស់ខ្លួនឲ្យព្រះអង្គ صلوات الله عليه والسلام សោយ ហើយព្រះអង្គ صلوات الله عليه والسلام បានអញ្ជើញពួកគាត់ទៅទទួលទានបាយនៅឯដំណាក់ព្រះអង្គ صلوات الله عليه والسلام ។

ជនក្រីក្រទាំងនោះក៏បានយល់ព្រម ។ ពេលមកដល់ផ្ទះអ៊ីម៉ាំហ្សាសាន់ صلوات الله عليه والسلام អ៊ីម៉ាំហ្សាសាន់ صلوات الله عليه والسلام បានទទួលជនក្រីក្រដោយសេចក្តីគោរព ។ គេបានលើកម្ហូបឆ្ងាញ់ៗមកដាក់ឲ្យពួកគាត់បរិភោគ ។

ឧត្តមគតិរឿងនេះគឺៈ

១) បើគេឲ្យអ្វីមួយមកអ្នក ចូរទទួលយកដោយអរគុណគេ ទោះបីអ្នកមិនចង់បានក៏ដោយ ។

២) ចូរព្យាយាមឲ្យគេវិញលើសពីគេឲ្យមកអ្នក ។

## លំហាត់ ៦ក

# អ៊ីម៉ាំហាសាន់ صلوات الله عليه والسلام

អ៊ីម៉ាំ ហាសាន់ صلوات الله عليه والسلام ប្រសូតនៅឯម៉ាឌីណាស់ ថ្ងៃទី ១៥ ខែរ៉ម៉ាដូន ឆ្នាំ ៣ សកករាជហ៊ីចរ៉េះត៍ ត្រូវនឹងថ្ងៃទី ១/៣/៦២៥ នៃគ្រិស្តសករាជ ។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គតនៅម៉ាឌីណាស់ ថ្ងៃទី ២៨ ខែស្វ៍ហ្វារ ឆ្នាំ ៥០ សកករាជហ៊ីជ្ជរ៉េះត៍ ត្រូវនឹងថ្ងៃទី ៦/៣/៦៧០ នៃគ្រិស្តសករាជ ។



# លំហាត់ ៦ខ

ចូរនិយាយឲ្យឪពុកម្ដាយអ្នកស្ដាប់រឿងអ៊ីម៉ាំទី ២ របស់យើង អ៊ីម៉ាំហ៊ាសាន់ صلوات الله عليه والسلام អង្គុយបរិភោគបាយជាមួយអ្នកក្រខ្សត់ ។



បន្ទាប់ពីនោះ អ៊ីម៉ាំ صلوات الله عليه والسلام បានអញ្ជើញជនក្រីក្រទៅបរិភោគបាយនៅឯផ្ទះព្រះអង្គ صلوات الله عليه والسلام ។ ចូរស្មានមើលថាតើមានម្ហូបអ្វីខ្លះ ចូរគូររូបម្ហូបទាំងនោះនៅលើតុ ។





## មេរៀនទី ៧

# អ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام

អ៊ីម៉ាំទី ៣ របស់យើង គឺអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام ជាបុគ្គលប្រសើរណាស់ ។ ព្រះអង្គ صلوات الله عليه والسلام បារម្ភអ្នកដទៃមុនខ្លួនឯងជានិច្ច ។

កាលអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام ធ្វើដំណើរទៅការបាឡាអ៊ុំ ដោយដឹងច្បាស់ថានឹងមាន អ្វីកើតឡើងដល់ព្រះអង្គ صلوات الله عليه والسلام និងគ្រួសារព្រះអង្គ صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام បានជួប ហ៊ួរ (اَلْحُرَّ بْنَ يَزِيدَ اَلرِّيَاحِيَّ) និងកងទ័ព ។

អ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام ដឹងថា នេះគឺកងទ័ពដែលយ៉ាស៊ីដ្ឋបានចាត់បញ្ជូនមកវាយ ព្រះអង្គ صلوات الله عليه والسلام និងបណ្ដាអ្នកតាមព្រះអង្គ صلوات الله عليه والسلام នេះគឺកងទ័ពដែលនឹងរាំាំងព្រះអង្គ صلوات الله عليه والسلام និងបណ្ដាបក្សពួកព្រះអង្គ صلوات الله عليه والسلام មិនឲ្យទៅដងទឹកទេ នេះគឺកងទ័ពដែលនឹង សម្លាប់ព្រះអង្គ صلوات الله عليه والسلام គ្រួសារព្រះអង្គ صلوات الله عليه والسلام និងមិត្តព្រះអង្គ صلوات الله عليه والسلام ។

ទោះបីអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام ដឹងទាំងអស់នេះក៏ដោយ ពេលអ៊ីម៉ាំ صلوات الله عليه والسلام ឃើញទ័ព របស់ហ៊ួរកំពុងស្រេកទឹកខ្លាំង ហើយព្រះអង្គ صلوات الله عليه والسلام ឃើញថាពួកគេមិនមានទឹកផឹកទេ អ៊ីម៉ាំ صلوات الله عليه والسلام បានបញ្ជាឲ្យរេហ៍ពលរបស់ព្រះអង្គ صلوات الله عليه والسلام ឲ្យទឹកទៅទ័ពរបស់ហ៊ួរផឹក ។

អ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام និងរេហ៍ពលព្រះអង្គ صلوات الله عليه والسلام មិនត្រឹមតែឲ្យទឹកទ័ពរបស់ហ៊ួរផឹក ទេ ថែមទាំងឲ្យទឹកសេះពួកគេនោះផឹកទៀតផង ។

ឧត្តមគតិរឿងនេះគឺ ទោះបីអ្នកណាមួយធ្វើអាក្រក់មកលើអ្នកក៏ដោយ អ្នកត្រូវ ប្រព្រឹត្តដោយមេត្រីភាពចំពោះអ្នកនោះជានិច្ច ព្រោះអល់ឡោះហ្វ៍ عز وجل បង្ហាត់បង្រៀន យើងឲ្យធ្វើដូច្នេះ ។

## លំហាត់ ៧ក

# អ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام

អ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام ប្រសូតនៅឯម៉ាឌីណាស្ហ៍ ថ្ងៃទី ៣ ខែ ស្ហាក់បាន ឆ្នាំ ៤ សករាជហ៊ីជ្រ៉ោះត៍ ត្រូវនឹងថ្ងៃទី ៨/១/៦២៦ នៃគ្រិស្តសករាជ។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គតនៅនគរការបាឡាអ៍ ថ្ងៃទី ១០ ខែ មូហារ៉ម ឆ្នាំ ៦១ សករាជហ៊ីជ្រ៉ោះត៍ ត្រូវនឹងថ្ងៃទី ១០/១០/៦៨០ ។



## លំហាត់ ៧ខ

ចូរនិយាយឲ្យឪពុកម្តាយស្តាប់នូវរឿងអ៊ីម៉ាំហ៊្សែសែន៍ صلوات الله عليه والسلام ឲ្យទឹកហ៊្សូរ កងទ័ព របស់ហ៊្សូរនិងសេះកងទ័ពនោះផឹក ទោះបីព្រះអង្គ صلوات الله عليه والسلام ដឹងថាពួកនេះនឹងសម្លាប់ព្រះអង្គ صلوات الله عليه والسلام គ្រួសារនិងមិត្តព្រះអង្គ صلوات الله عليه والسلام ក៏ដោយ ។



## មេរៀនទី ៨

# អ៊ីម៉ាំ អាលី ស៊ែនុល-អាប៊ីឌីន صلوات الله عليه والسلام

អ៊ីម៉ាំទី ៤ របស់យើង គឺអ៊ីម៉ាំ អាលី ស៊ែនុល-អាប៊ីឌីន صلوات الله عليه والسلام ចងចាំជានិច្ចព្រះវចនៈរបស់ព្រះសាស្ដា صلى الله عليه وآله وسلم ថា៖ មុស្លីមណាដែលមិនគិតដល់សេចក្ដីត្រូវការរបស់មុស្លីមឯទៀតទេ មុស្លីមនោះមិនមែនមុស្លីមទេ ។

ហេតុដូច្នេះឯងបានជា ពេលយប់ ពេលគេដេកលក់អស់ អ៊ីម៉ាំ អាលី ស៊ែនុល-អាប៊ីឌីន صلوات الله عليه والسلام ភ្ញាក់ពីដំណេក ដាក់គ្រឿងបរិភោគក្នុងថង់ហើយលីថង់អាហារនោះលើស្មាទៅដាក់ឯផ្ទះជនទ័លក្រ ។

ពេលអ៊ីម៉ាំ អាលី ស៊ែនុល-អាប៊ីឌីន صلوات الله عليه والسلام ចេញពីផ្ទះ ពេលនោះយប់ងងឹត មនុស្សដេកលក់អស់ តែអ៊ីម៉ាំ صلوات الله عليه والسلام បិទមុខបង្ការក្រែងលោមានអ្នកណាមិនដេកនឹងស្គាល់មុខព្រះអង្គ صلوات الله عليه والسلام ។

អ៊ីម៉ាំ អាលី ស៊ែនុល-អាប៊ីឌីន صلوات الله عليه والسلام មើលថែរក្សាមនុស្សប្រមាណ ១០០ គ្រួសារ បែបនេះឯង ពុំមានអ្នកណាមួយដឹងថាអ្នកណាជួយជ្រោមជ្រែងខ្លួនទេ ។

លុះពេលអ៊ីម៉ាំ អាលី ស៊ែនុល-អាប៊ីឌីន صلوات الله عليه والسلام សោយទិវង្គត ហើយមនុស្សលែងបានទទួលជំនួយ ទើបគេដឹងថាអ៊ីម៉ាំ អាលី ស៊ែនុល-អាប៊ីឌីន صلوات الله عليه والسلام ជាអ្នកជួយពួកគេតាំងពីដើមមក ។

ឧត្តមគតិរឿងនេះគឺ៖

ពេលអ្នកធ្វើអំពើល្អប្រការណាមួយ ចូរកុំដើរប្រកាសឲ្យគេឯងដឹងឮ ព្រោះអល់ឡោះហ៍ عز وجل ឃើញ ព្រះអង្គ عز وجل នឹងតបស្នងទង្វើអ្នក ។ ការពិត អល់ឡោះហ៍ عز وجل មានព្រះបន្ទូលថាពេលអ្នកធ្វើអំពើល្អប្រការណាមួយដោយមិនប្រាប់ឲ្យគេដឹងឮ ព្រះអង្គ عز وجل នឹងតបស្នងអ្នកច្រើនលើសប្រការល្អនោះ ។

**លំហាត់ ៨ក**

# អ៊ីម៉ាំ អាលី ស៊ែនុល-អាប៊ីឌីន صلوات الله عليه والسلام

អ៊ីម៉ាំ អាលី ស៊ែនុល-អាប៊ីឌីន صلوات الله عليه والسلام ប្រសូតនៅឯម៉ាឌីណាស់ ថ្ងៃទី ៥ ខែស្ហាក់បាន ឆ្នាំ ៣៨ សកករាជហ៊ីជ្ជរ៉ោះត៍ ត្រូវនឹងថ្ងៃទី ៦/១/៦៥៩ នៃគ្រិស្តសករាជ ។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គតនៅម៉ាឌីណាស់ ថ្ងៃទី ២៥ មូហារ៉ម ឆ្នាំ ៩៥ សកករាជហ៊ីជ្ជរ៉ោះត៍ ត្រូវនឹងថ្ងៃទី ២០/១០/៧១៣ នៃគ្រិស្តសករាជ ។

ព្រះបិតា ៖
អ៊ីម៉ាំហ៊ូស៊ែន៍ صلوات الله عليه والسلام

មាតា ៖
ប៊ីប៊ី ស្ហាស់រ៉បាន្ង (شَهْرَبَانُو)

**អ៊ីម៉ាំ អាលី ស៊ែនុល-អាប៊ីឌីន صلوات الله عليه والسلام**

ព្រះរាជបុត្រ ៖
អ៊ីម៉ាំ មូហាំម៉ាដ៉ូ អាល់-បាក្វៀរ صلوات الله عليه والسلام

## លំហាត់ ៨ខ

ពេលអ្នកធ្វើប្រការល្អ ចូរកុំដើរប្រាប់គេ ។ អល់ឡោះហ្វ៍ عز وجل មួយគត់ដែលដឹង អល់ឡោះហ្វ៍ عز وجل ទ្រង់ញាណសព្វសារពើដោយមិនបាច់គេប្រាប់ ។



ចូរផាត់ពណ៌អូប៉ាល័រ ហើយផ្ទឹតផ្ទង់ផាត់ពណ៌សញ្ញាខ្វែងដើម្បីឲ្យដឹងថាមិនបាច់ឲ្យគេដឹងទេថាអ្នកបានធ្វើប្រការល្អ ។

**មេរៀនទី ៩**

# អ៊ីមុាំ មូហាំម៉ាដ់ អាល់-បាកៀរ صلوات الله عليه والسلام

កណ្ដាលថ្ងៃក្ដៅ អ៊ីមុាំទី ៥ របស់យើង គឺអ៊ីមុាំ មូហាំម៉ាដ់ អាល់-បាកៀរ صلوات الله عليه والسلام ប្រកបកិច្ចការចម្ការព្រះអង្គ صلوات الله عليه والسلام យ៉ាងលំបាក ។

បុរសម្នាក់បានដើរកាត់តាមនោះ ឃើញអ៊ីមុាំ មូហាំម៉ាដ់ អាល់-បាកៀរ صلوات الله عليه والسلام រងកម្ដៅថ្ងៃនិងនឿយហត់ខ្លាំងដោយការកាប់គាស់ចម្ការ ក៏បានប្រាប់ព្រះអង្គ صلوات الله عليه والسلام ថាព្រះអង្គ صلوات الله عليه والسلام មិនត្រូវធ្វើការធ្ងន់បែបនេះទេ ព្រះអង្គ صلوات الله عليه والسلام គប្បីសម្រាក ។

អ៊ីមុាំ មូហាំម៉ាដ់ អាល់-បាកៀរ صلوات الله عليه والسلام បានតបបុរសនោះថាព្រះអង្គ صلوات الله عليه والسلام ប្រកបកិច្ចការធ្ងន់ដើម្បីចិញ្ចឹមគ្រួសារព្រះអង្គ صلوات الله عليه والسلام មិនចង់សូមជំនួយពីអ្នកដទៃទេ ។

អល់ឡោះហ្ عز وجل ទ្រង់សព្វព្រះហឫទ័យដែលយើងប្រកបកិច្ចការធ្ងន់ ដែលយើងពឹងពាក់ខ្លួនឯង ។

ឧត្តមគតិរឿងនេះគឺ៖

អ្នកត្រូវព្យាយាមធ្វើដោយខ្លួនឯងជានិច្ច ។ លុះត្រាតែអ្នកបានសាកល្បងធ្វើតែមិនអាចធ្វើបាន ទើបអ្នកសូមជំនួយ ។

**លំហាត់ ៩ក**

# អ៊ីម៉ាំ មូហាំម៉ាដ់ អាល់-បាគៀរ صلوات الله عليه والسلام

អ៊ីម៉ាំ មូហាំម៉ាដ់ អាល់-បាគៀរ صلوات الله عليه والسلام ប្រសូតនៅឯម៉ាឌីណាស់ ថ្ងៃទី ១ ខែរ៉យ៉ាប់ ឆ្នាំ ៥៧ សករាជហ៊ីជ្រ៉ោះត៍ ត្រូវនឹងថ្ងៃទី ១៦/១២/៦៧៦ នៃគ្រិស្តសករាជ ។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គតនៅម៉ាឌីណាស់ ថ្ងៃ ទី ៧ ខែ ស៊ុលហ៊ីជ្ជយ៉ាស់ ឆ្នាំ ១១៤ សករាជហ៊ីជ្រ៉ោះត៍ ត្រូវនឹងថ្ងៃទី ២៨/០១/៧៣៣ នៃគ្រិស្តសករាជ ។ ។

ព្រះបិតា ៖
អ៊ីម៉ាំ អាលី ស៊ែនុល-អាប៊ីឌីន صلوات الله عليه والسلام

មាតា ៖
ប៊ីប៊ី ហ្វាទីម៉ាស់ ប៊ិនទី អាល់-ហាសាន់

**អ៊ីម៉ាំ មូហាំម៉ាដ់ អាល់-បាគៀរ صلوات الله عليه والسلام**

ព្រះរាជបុត្រ ៖
អ៊ីម៉ាំ យ៉ាក់ហ្វារ អាស្វ-ស្វ៉ាឌិក صلوات الله عليه والسلام

## លំហាត់ ៩ខ

ចូរនិយាយប្រាប់ឪពុកម្តាយអ្នកថាហេតុអ្វីអ៊ីមុាំ មូហ៊ាំម៉ាដ់ អាល់-បាគៀរ صلوات الله عليه والسلام ធ្វើការចម្ការធូន់ក្នុងចម្ការព្រះអង្គ صلوات الله عليه والسلام ។









ចូរអ្នកគូរការងារដែលអ្នកអាចធ្វើបានដើម្បីជួយគ្រួសារអ្នក ។

## មេរៀនទី ១០

# អ៊ីម៉ាំ យ៉ាក់ហ្វារ អាស្ស-ស្វ៉ឌិក្ក صلوات الله عليه والسلام

ថ្ងៃមួយ អ៊ីម៉ាំទី ៦ របស់យើង គឺអ៊ីម៉ាំ យ៉ាក់ហ្វារ អាស្ស-ស្វ៉ឌិក្ក صلوات الله عليه والسلام អង្គុយជាមួយមិត្តមួយក្រុម បរិភោគទំពាំងបាយជូរ បុរសម្នាក់បានមកសូមឲ្យព្រះអង្គ صلوات الله عليه والسلام ជួយ ។

អ៊ីម៉ាំ យ៉ាក់ហ្វារ អាស្ស-ស្វ៉ឌិក្ក صلوات الله عليه والسلام បានឲ្យបុរសនោះទំពាំងបាយជូរមួយចង្កោម ។ បុរសនោះមិនព្រមទទួលយកទំពាំងបាយជូរទេ គាត់សូមប្រាក់ពីអ៊ីម៉ាំ صلوات الله عليه والسلام ។

អ៊ីម៉ាំ យ៉ាក់ហ្វារ អាស្ស-ស្វ៉ឌិក្ក صلوات الله عليه والسلام ប្រាប់គាត់ថាអល់ឡោះហ្វ៍ عزوجل នឹងឲ្យប្រាក់គាត់ ។ បុរសនោះក៏បានដើរចេញតែគាត់ត្រឡប់មកវិញសូមទំពាំងបាយជូរ ។ អ៊ីម៉ាំ صلوات الله عليه والسلام ប្រាប់គាត់ថាអល់ឡោះហ្វ៍ عزوجل នឹងឲ្យគាត់ទំពាំងបាយជូរនោះ ។

មួយស្របក់ក្រោយមក បុរសក្រីក្រម្នាក់ទៀតចូលមកសូមជំនួយពីអ៊ីម៉ាំ យ៉ាក់ហ្វារ អាស្ស-ស្វ៉ឌិក្ក صلوات الله عليه والسلام ។ អ៊ីម៉ាំ صلوات الله عليه والسلام ហុចទំពាំងបាយជូរមួយចង្កោមឲ្យគាត់ ។ បុរសនោះទទួលយកទំពាំងបាយជូរហើយអរព្រះគុណអល់ឡោះហ្វ៍ عزوجل ។

បន្ទាប់មកអ៊ីម៉ាំ យ៉ាក់ហ្វារ អាស្ស-ស្វ៉ឌិក្ក صلوات الله عليه والسلام ឲ្យប្រាក់បុរសនោះ គាត់ក៏អរព្រះគុណអល់ឡោះហ្វ៍ عزوجل ម្តងទៀត ។ អ៊ីម៉ាំ صلوات الله عليه والسلام បានឲ្យបុរសនោះអាវព្រះអង្គ صلوات الله عليه والسلام គាត់ក៏បានទទួលយកអាវនោះហើយត្រឡប់ទៅវិញដោយជូនសាធុការពរអ៊ីម៉ាំ صلوات الله عليه والسلام ។

បើបុរសនោះនៅតែអរព្រះគុណអល់ឡោះហ្វ៍ عزوجل ដែលអ៊ីម៉ាំ صلوات الله عليه والسلام បានបរិច្ចាគឲ្យគាត់នោះ អ៊ីម៉ាំ صلوات الله عليه والسلام ប្រាកដជានឹងនៅតែឲ្យគាត់តទៀតលុះត្រាតែអស់របស់ពីខ្លួន ។

ឧត្តមគតិរឿងនេះគឺ ពេលអ្នកទទួលបានអ្វីមួយ ទោះបីពីអ្នកណាក៏ដោយ ចូរអ្នកចងចាំថាអល់ឡោះហ្វ៍ عزوجل ទេដែលចង់ឲ្យអ្នកទទួលបាននូវអ្វីនោះ ។ ដូច្នេះអ្នកមិនត្រឹមតែអរគុណអ្នកនោះម្នាក់ទេដែលដាក់អំណោយឲ្យអ្នក (ដោយថាយ៉ាស្វាកាល់ឡោះហ្វ៍) តែអ្នកត្រូវអរព្រះគុណអល់ឡោះហ្វ៍ عزوجل ទៀតផង (ដោយថា អាល់-

ហ៊ាំឌូលិលឡាស្វ់) ។

**លំហាត់ ១០ក**

# អ៊ីម៉ាំ យ៉ាក់ហ្វារ អាស់-ស្វ៏ឌិក្វ صلوات الله عليه والسلام

អ៊ីម៉ាំ យ៉ាក់ហ្វារ អាស់-ស្វ៏ឌិក្វ صلوات الله عليه والسلام ប្រសូតនៅឯម៉ាឌីណាស់ ថ្ងៃទី ១៧ ខែ រ៉ប៊ីអ៊ុល អាវ៉ាល់ ឆ្នាំ ៨៣ សកករាជហ៊ីជ្រ៉េះត៍ (ដូចថ្ងៃកំណើតព្រះសាស្ដា صلى الله عليه وآله وسلم យើងដែរ) ត្រូវនឹងថ្ងៃទី ២០/០៤/៧០២ នៃគ្រិស្តសករាជ ។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គត នៅម៉ាឌីណាស់ ថ្ងៃទី ២៥ ខែ ស្ហៅវ៉ាល់ ឆ្នាំ ១៤៨ សកករាជហ៊ីជ្រ៉េះត៍ ត្រូវនឹងថ្ងៃទី ១៤/១២/៧៦៥ នៃគ្រិស្តសករាជ ។

ព្រះបិតា ៖
អ៊ីម៉ាំ មូហាំម៉ាដ់ អាល់-បាគៀរ صلوات الله عليه والسلام

មាតា ៖
ប៊ីប៊ី ហ្វាទីម៉ាស់ (أم فروة بنت القاسم អ៊ូម ហ្វារវ៉ាស់)

អ៊ីម៉ាំ យ៉ាក់ហ្វារ អាស់-ស្វ៏ឌិក្វ صلوات الله عليه والسلام

ព្រះរាជបុត្រ ៖
អ៊ីម៉ាំ មូសា អាល់-កាស្ហ៊ីម صلوات الله عليه والسلام

**លំហាត់ ១០ខ**

ចូរនិយាយប្រាប់ឪពុកម្ដាយអ្នកថាហេតុអ្វីអ៊ីម៉ាំទី ៦ របស់យើង អ៊ីម៉ាំ យ៉ាក្គុំហ្វារ អាស្វ៉-ស្វ៏ឌិក្ក صلوات الله عليه والسلام ឲ្យបុរសទីពីរយ៉ាងច្រើន ឲ្យបុរសទីមួយតិចជាងគេ ។

ចូរផាត់ពណ៌ផ្លែទំពាំងបាយជូរ ហើយគូររបស់ឯទៀតដែលអ៊ីម៉ាំ صلوات الله عليه والسلام បានឲ្យទៅបុរសទីពីរ ។







## មេរៀនទី ១១

# អ៊ីមុាំ មូសា អាល់-កាស្ស៊ីម صلوات الله عليه والسلام

ថ្ងៃមួយ អ៊ីមុាំទី ៧ របស់យើង គឺអ៊ីមុាំ មូសា អាល់-កាស្ស៊ីម صلوات الله عليه والسلام បានដើរហួសបុរសក្រីក្រម្នាក់ ។ អ៊ីមុាំ صلوات الله عليه والسلام បានឲ្យសាឡាមគាត់ បាននិយាយជាមួយគាត់មួយស្របក់ដោយសួរគាត់ថាតើគាត់សុខសប្បាយជាទេ ។

ពេលលាគ្នា អ៊ីមុាំ មូសា អាល់-កាស្ស៊ីម صلوات الله عليه والسلام បានប្រាប់គាត់ថាបើមានអ្វីមួយដែលព្រះអង្គ صلوات الله عليه والسلام អាចជួយបាន ព្រះអង្គ صلوات الله عليه والسلام នឹងជួយគាត់ដោយពេញចិត្ត ។

បណ្ដាសាវករបស់អ៊ីមុាំ صلوات الله عليه والسلام បានឃើញ និងឮអ៊ីមុាំ صلوات الله عليه والسلام រាក់ទាក់ជាមួយបុរសក្រីក្រនេះដែលជាមនុស្សសាមញ្ញ ។ ពួកសាវកក៏បានប្រាប់អ៊ីមុាំ صلوات الله عليه والسلام ថាមនុស្សវណ្ណខ្ពស់ដូចអ៊ីមុាំ صلوات الله عليه والسلام មិនស័ក្តិសមនិយាយនិងបម្រើវណ្ណដូចបុរសនោះទេ ។

អ៊ីមុាំ មូសា អាល់-កាស្ស៊ីម صلوات الله عليه والسلام បានឆ្លើយពួកសាវកនោះថាពួកគេភ្លេចគិតថាមនុស្សទាំងអស់ជាបម្រើរបស់អល់ឡោះហ្ទ័ عز وجل ថាអល់ឡោះហ្ទ័ عز وجل បង្កើតមនុស្សទាំងអស់ស្មើគ្នា ។ ម្យ៉ាងទៀត បើអ្នកណាក្រថ្ងៃនេះមិនបានសេចក្ដីថាអ្នកនោះនៅតែក្ររហូតមួយជីវិតទេ ឯអ្នកមានក៏ដូច្នេះដែរ ។ ដូច្នេះ អ្នកដែលសូមជំនួយពីអស់លោកថ្ងៃនេះអាចជាអ្នកដដែលដែលនឹងជួយអស់លោកក្នុងថ្ងៃមុខ ។

ឧត្តគតិរឿងនេះគឺៈ

១) ក្នុងសាសនាអ៊ីស្លាម មនុស្សទាំងអស់ស្មើគ្នា ។

២) អល់ឡោះហ្ទ័ عز وجل ជាអ្នកប្រទានឲ្យ ថ្ងៃមុខអ្នកដទៃអាចមានអ្វីដែលអ្នកកំពុងមានថ្ងៃនេះដែរ ។

**លំហាត់ ១១ក**

# អ៊ីម៉ាំ មូសា អាល់-កាសظ៊ីម صلوات الله عليه والسلام

អ៊ីម៉ាំ មូសា អាល់-កាសظ៊ីម صلوات الله عليه والسلام ប្រសូតនៅឯស្រុកអាប់វ៉ាអ៍ ថ្ងៃទី ៧ ខែ ស្ហ្វហ្វារ ឆ្នាំ ១២៨ សកករាជហ៊ីជរ៉ោះត៍ (ខែស្ហ្វហ្វារជាខែកាន់ទុក្ខ គេធ្វើបុណ្យខួបកំណើតព្រះអង្គ صلوات الله عليه والسلام ថ្ងៃទី ៧ ខែ ៧ ពីព្រោះព្រះអង្គ صلوات الله عليه والسلام ជាអ៊ីម៉ាំទី ៧ របស់យើង) ត្រូវនឹងឆ្នាំ ៧៤៥ នៃគ្រិស្តសករាជ ។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គតនៅឯនគរបាក់ដ្ហាដ់ ថ្ងៃទី ២៥ ខែ រ៉យ៉ាជប់ ឆ្នាំ ១៨៣ សកករាជហ៊ីជរ៉ោះត៍ ត្រូវនឹងថ្ងៃទី ០១/០៩/៧៩៩ នៃគ្រិស្តសករាជ ។

ព្រះបិតា ៖
អ៊ីម៉ាំ យ៉ាជក់ហ្វារ អាស្ស-ស្ហ្វឌិក្ق صلوات الله عليه والسلام

មាតា ៖
ប៊ីប៊ី ហាحមីដ្ហាស់ (حَمِيدَة)

**អ៊ីម៉ាំ មូសា អាល់-កាសظ៊ីម صلوات الله عليه والسلام**

រាជបុត្រី ៖
ប៊ីប៊ី ហ្វាطទីម៉ាស់ អាល់-ម៉ាក់ស៊្ហម៉ាស់
(فاطمة المعصومة)

ព្រះរាជបុត្រ ៖
អ៊ីម៉ាំ អាលី អារ-រីضឌ៏ صلوات الله عليه والسلام

# លំហាត់ ១១ខ

ចូរអ្នកនិយាយប្រាប់ឪពុកម្តាយអ្នកថាហេតុអ្វីអ៊ីម៉ាំទី ៧ របស់យើង អ៊ីម៉ាំ មូសា អាល់-កាស៊្ទីម صلوات الله عليه والسلام យកចិត្តទុកដាក់នឹងមនុស្សសាមញ្ញ ។

មនុស្សទាំងអស់នេះ ដែលមានមាតុប្រទេសខុសគ្នានោះ តើមនុស្សមួយណាប្រសើរជាងគេ ?



## មេរៀនទី ១២

# អ៊ីម៉ាំ អ៊ាលី អារ-រីដ្ហ៍ضصلوات الله عليه والسلام

រាស្ត្ររបស់ស្តេចម៉ាក់មូនក្រេវក្រោធខ្លាំងណាស់ ព្រោះតែស្តេចរូបនេះបានយកអ៊ីម៉ាំទី ៨ របស់យើង គឺអ៊ីម៉ាំ អ៊ាលី អារ-រីដ្ហ៍ضصلوات الله عليه والسلام ជាអ្នកស្នងរាជ្យបន្ទាប់ពីខ្លួន ។

ដើម្បីបង្ហាញអ៊ីម៉ាំ អ៊ាលី អារ-រីដ្ហ៍ضصلوات الله عليه والسلامថាពួកគេមិនគោរពព្រះអង្គصلوات الله عليه والسلامទេ ពួកបរិវាររបស់ស្តេចម៉ាក់មូនបានសម្រេចចិត្តថាពេលអ៊ីម៉ាំصلوات الله عليه والسلامមកឯវាំង ពួកគេនឹងមិនបើកទ្វារឲ្យអ៊ីម៉ាំصلوات الله عليه والسلامទេ មិនលើកវាំងននឲ្យព្រះអង្គصلوات الله عليه والسلامចូលទេ ។

ថ្ងៃនោះ ពេលអ៊ីម៉ាំ អ៊ាលី អារ-រីដ្ហ៍ضصلوات الله عليه والسلامមកឯវាំង ទ្វារនិងវាំងននបើកឲ្យអ៊ីម៉ាំصلوات الله عليه والسلامដោយខ្លួនឯងក្រោមព្រះបញ្ជាអល់ឡោះហ្ទ៍عز وجل ។

ពួកបម្រើភ័យស្លន់ស្លោថៃមទាំងខ្មាស់ ហើយក៏ប្រញាប់ទៅកាន់មុខការបើកទ្វារនិងបើកវាំងននឲ្យអ៊ីម៉ាំصلوات الله عليه والسلامវិញ ។

ឧត្តមគតិរឿងនេះគឺ ពុំមានអ្នកណាអាចបៀតបៀនអ្នកបានទេបើអល់ឡោះហ្ទ៍عز وجلថែរក្សាអ្នក ព្រោះអល់ឡោះហ្ទ៍عز وجلខ្លាំងពូកែបំផុត ព្រះអង្គعز وجلគ្រប់គ្រងអ្វីៗទាំងអស់ ។

## លំហាត់ ១២ក

# អ៊ីម៉ាំ អាលី អារ-រីដ្ហ៍ صلوات الله عليه والسلام

អ៊ីម៉ាំ អាលី អារ-រីដ្ហ៍ صلوات الله عليه والسلام ប្រសូតនៅឯម៉ាឌីណាស់ ថ្ងៃទី ១១ ខែ ហ្ស៊ុលកាអ៊ីដាស់ ឆ្នាំ ១៤៨ សករាជហ៊ីជ្រោះត៍ ត្រូវនឹងថ្ងៃទី ២៩/១២/៧៦៥ ឬ ០១/០១/៧៦៦ នៃគ្រិស្តសករាជ ។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គតនៅស្រុកម៉ាស្ហាដ់ ប្រទេសអ៊ីរ៉ង់ ថ្ងៃទី ២៩ ខែ ស្វ័ហ្វារ ឆ្នាំ ២០៣ សករាជហ៊ីជ្រោះត៍ ត្រូវនឹងថ្ងៃទី ២៦/០៥/៨១៩ នៃគ្រិស្តសករាជ ។

ព្រះបិតា ៖
អ៊ីម៉ាំ មូសា អាល់-កាស្ហ៊ីម صلوات الله عليه والسلام

មាតា ៖
ប៊ីប៊ី អ៊ូមុល-បានីន ណាជ់ម៉ាស់
(أُمّ ٱلْبَنِين نجمة)

អ៊ីម៉ាំ អាលី អារ-រីដ្ហ៍ صلوات الله عليه والسلام

ព្រះរាជបុត្រ ៖
អ៊ីម៉ាំ មូហាំម៉ាដ់ អាត់-តាគ្គី صلوات الله عليه والسلام

# លំហាត់ ១២ខ

ចូរនិយាយប្រាប់ឪពុកម្ដាយអ្នកថាមានអ្វីកើតឡើង ពេលពួកបម្រើកំណាចមិនបើកទ្វារនិងរាំងននឲ្យអ៊ីម៉ាំទី ៨ របស់យើង អ៊ីម៉ាំ អាុលី អារ-រីដ្ហ៍ صلوات الله عليه والسلام ។





## មេរៀនទី ១៣

# អ៊ីម៉ាំ មូហាំម៉ាដ់ អាត់-តាគ្គី صلوات الله عليه والسلام

កាលអ៊ីម៉ាំទី ៩ របស់យើង គឺអ៊ីម៉ាំ មូហាំម៉ាដ់ អាត់-តាគ្គី صلوات الله عليه والسلام អាយុ ៩ ឆ្នាំ ព្រះបិតាព្រះអង្គ صلوات الله عليه والسلام អ៊ីម៉ាំទី ៨ របស់យើង គឺអ៊ីម៉ាំ អាលី អារ-រីដ្ហ៍ صلوات الله عليه والسلام ត្រូវស្ដេចម៉ាក់មូនសម្លាប់ ។

ស្ដេចម៉ាក់មូនគិត "ទិញ" (សូក) អ៊ីម៉ាំ មូហាំម៉ាដ់ អាត់-តាគ្គី صلوات الله عليه والسلام ដើម្បីទាញព្រះអង្គ صلوات الله عليه والسلام មកនៅក្នុងរបៀបរស់នៅដូចខ្លួនដែរ ព្រោះអ៊ីម៉ាំ صلوات الله عليه والسلام នៅក្មេងនៅឡើយ ។

ស្ដេចម៉ាក់មូនបាននាំអ៊ីម៉ាំ មូហាំម៉ាដ់ អាត់-តាគ្គី صلوات الله عليه والسلام ទៅវាំង ឲ្យព្រះអង្គ صلوات الله عليه والسلام អ្វីៗសព្វគ្រប់ដែលប្រាក់អាចទិញបាន តែអ៊ីម៉ាំ صلوات الله عليه والسلام មិនយកចិត្តទុកដាក់ទេព្រោះព្រះអង្គ صلوات الله عليه والسلام ដឹងថាអល់ឡោះហ៍ عزّ وجلّ អាចឲ្យព្រះអង្គ صلوات الله عليه والسلام ច្រើនលើសនោះ ។

ទោះបីស្ដេចម៉ាក់មូនឲ្យព្រះអង្គ صلوات الله عليه والسلام អ្វីក៏ដោយ ក៏អ៊ីម៉ាំ صلوات الله عليه والسلام មិនធ្វើអ្វីមួយឡើយដែលទាស់នឹងព្រះបំណងរបស់អល់ឡោះហ៍ عزّ وجلّ តាមបំណងរបស់ស្ដេចម៉ាក់មូននោះ ។

ឧត្ដមគតិរឿងនេះគឺ ទោះបីគេឲ្យអ្នកច្រើនប៉ុណ្ណាក៏ដោយ ចូរចងចាំថាអល់ឡោះហ៍ عزّ وجلّ អាចឲ្យអ្នកច្រើនបំផុតបើអ្នកជាមុស្លីមល្អ ធ្វើតាមអល់ឡោះហ៍ عزّ وجلّ ប្រាប់ ។

**លំហាត់ ១៣ក**

# អ៊ីមុាំ មូហ៊ាំម៉ាដ់ អាត់-តាគ្គី صلوات الله عليه والسلام

អ៊ីមុាំ មូហ៊ាំម៉ាដ់ អាត់-តាគ្គី صلوات الله عليه والسلام ប្រសូតនៅឯម៉ាឌីណាស់ ថ្ងៃទី ១០ ខែ រ៉យ៉ាប់ ឆ្នាំ ១៩៥ សករាជហ៊ីជ្រ៉ោះត៍ ត្រូវនឹងថ្ងៃទី ១២/០៤/៨១១ នៃគ្រិស្តសករាជ ។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គតនៅស្រុកកាស៊ីម៉ែន៍ (ٱلْكَاظِمَيْن ប្រទេសអ៊ីរ៉ាក់) ថ្ងៃទី ២៩ ខែ ស៊ុលក្ញុំដាស់ ឆ្នាំ ២២០ សករាជហ៊ីជ្រ៉ោះត៍ ត្រូវនឹងថ្ងៃទី ២៧/១១/៨៣៥ នៃគ្រិស្តសករាជ ។



## លំហាត់ ១៣ខ

បើគេឲ្យអ្នករបស់អស់នេះ តើអ្នកស្តាប់អ្នកនោះឬស្តាប់អល់ឡោះ عز وجل ? ហេតុអ្វី ?








តើអ៊ីម៉ាំទី ៩ របស់យើង អ៊ីម៉ាំ មូហ្ហាំម៉ាដ់ អាត់-តាគ្គី صلوات الله عليه والسلام ធ្វើអ្វីខ្លះពេលស្តេចម៉ាក់មូនចង់ទិញរបស់សព្វគ្រប់ឲ្យព្រះអង្គ صلوات الله عليه والسلام ?

## មេរៀនទី ១៤

# អ៊ីម៉ាំ អាលី អាន់-ណាគ្គី صلوات الله عليه والسلام

ថ្ងៃមួយ សម័យអ៊ីម៉ាំទី ១០ របស់យើង គឺអ៊ីម៉ាំ អាលី អាន់-ណាគ្គី صلوات الله عليه والسلام បុរសម្នាក់បានមកជួបព្រះអង្គ صلوات الله عليه والسلام ទូលព្រះអង្គ صلوات الله عليه والسلام ថាបើព្រះអង្គ صلوات الله عليه والسلام មិនជួយគាត់ទេ គេនឹងសម្លាប់គាត់ ។ អ៊ីម៉ាំ អាលី អាន់-ណាគ្គី صلوات الله عليه والسلام សូមឲ្យបុរសនោះនិយាយរឿងគាត់ប្រាប់ព្រះអង្គ صلوات الله عليه والسلام ។ បុរសនោះបានប្រាប់ថាស្តេចបានឲ្យគាត់ចារលើត្បូងមួយគ្រាប់ដ៏មានតម្លៃ ។

បុរសនោះបាននិយាយបន្តទៀតថាពេលគាត់សរសេរពីលើត្បូងនោះ ត្បូងនោះបែកជាពីរ បើស្តេចដឹងរឿងនេះស្តេចនោះនឹងសម្លាប់គាត់ ។

អ៊ីម៉ាំ អាលី អាន់-ណាគ្គី صلوات الله عليه والسلام បានបួងសួងអល់ឡោះហ៊្វ عز وجل ហើយបានប្រាប់បុរសនោះថាកុំបារម្ភ អល់ឡោះហ៊្វ عز وجل នឹងការពារគាត់ ។

ថ្ងៃបន្ទាប់មក ពេលស្តេចមកយកត្បូង បុរសនោះភ័យរន្ធត់ ។

ស្តេចបានប្រាប់បុរសនោះថាខ្លួនបានផ្លាស់ប្តូរចិត្តវិញ ថាខ្លួនចង់កាត់ត្បូងនោះជាពីរដើម្បីឲ្យទៅបុត្រីខ្លួនម្នាក់មួយចំហៀង ដោយចារអក្សរលើត្បូងទាំងពីរចំហៀងនោះ ។

ឧត្តមគតិរឿងនេះគឺ ទោះបីអ្នកជួបប្រទះបញ្ហាអ្វីក៏ដោយ អ្នកអាចពឹងពាក់អល់ឡោះហ៊្វ عز وجل បានជានិច្ច សូមឲ្យព្រះអង្គ عز وجل ជួយអ្នក ព្រោះអល់ឡោះហ៊្វ عز وجل ជាអ្នកធ្វើឲ្យព្រឹត្តិការណ៍គ្រប់សព្វកើតឡើងបាន ។

**លំហាត់ ១៤ក**

# អ៊ីម៉ាំ អាលី អាន់-ណាគ្វី صلوات الله عليه والسلام

អ៊ីម៉ាំ អាលី អាន់-ណាគ្វី صلوات الله عليه والسلام ប្រសូតនៅឯស្រុកស៊្វូរបាស្ង (ជិតម៉ាឌីណាស្ង) ថ្ងៃទី ១៥ ខែ ស៊ុលហ៊ីជ្ជយ៉ាស្ង ឆ្នាំ ២១២ សករាជហ៊ីជ្ជរ៉ោះគ្ង ត្រូវនឹងឆ្នាំ ៨២៨ នៃគ្រិស្តសករាជ ។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គតនៅឯស្រុក សាម៉ារ៉អ្ង (ប្រទេសអ៊ីរ៉ាក្វ) ថ្ងៃទី ៣ ខែ រ៉យ៉ាប់ ឆ្នាំ ២៥៤ សករាជហ៊ីជ្ជរ៉ោះគ្ង ត្រូវនឹងឆ្នាំ ៨៦៨ នៃគ្រិស្តសករាជ ។

ព្រះបិតា ៖
អ៊ីម៉ាំ មូហាំម៉ាដ្ង អាត់-តាគ្វី صلوات الله عليه والسلام

មាតា ៖
ប៊ីប៊ី ស្វម៉ាណាស្ង (سمانة المغربية)

អ៊ីម៉ាំ អាលី អាន់-ណាគ្វី صلوات الله عليه والسلام

ព្រះរាជបុត្រ ៖
អ៊ីម៉ាំ ហាសាន់ អាល់-អាស់ការី صلوات الله عليه والسلام

# លំហាត់ ១៤ខ

ចូរនិយាយប្រាប់ឪពុកម្តាយអ្នករឿងអ៊ីម៉ាំទី ១០ របស់យើង អ៊ីម៉ាំ អាុលី អាន់-ណាគ្គី صلوات الله عليه والسلام ជួយបុរសដែលបានធ្វើឲ្យត្បូងបែកជាពីរ ។



# មេរៀនទី ១៥

## អ៊ីម៉ាំ ហ៊ាសាន់ អាល់-អាស់ការី صلوات الله عليه والسلام

សម័យអ៊ីម៉ាំទី ១១ របស់យើង គឺអ៊ីម៉ាំ ហ៊ាសាន់ អាល់-អាស់ការី صلوات الله عليه والسلام មានបុរសម្នាក់មានប្រាក់ស្ដួចស្ដើងណាស់សម្រាប់ចិញ្ចឹមជីវិត ។

លុះដល់ពេលនេះបុរសនោះភ័យខ្លាច ពេលដែលប្រាក់ដ៏ស្ដួចស្ដើងនោះនឹងអស់ ។ ហេតុដូច្នេះ គាត់គិតយកប្រាក់នោះទៅកប់ទុកក្នុងដីនៅក្នុងសួនច្បារគាត់ ។

បុរសនោះបានមកជួបអ៊ីម៉ាំ ហ៊ាសាន់ អាល់-អាស់ការី صلوات الله عليه والسلام ទូលព្រះអង្គ صلوات الله عليه والسلام ថាគាត់មិនមានប្រាក់ទេ ថាគាត់ចង់ឲ្យអ៊ីម៉ាំ صلوات الله عليه والسلام ជួយគាត់ ។

អ៊ីម៉ាំ ហ៊ាសាន់ អាល់-អាស់ការី صلوات الله عليه والسلام បានឲ្យគាត់ប្រាក់មួយថង់ធំ ប្រាប់គាត់ថា អ៊ីម៉ាំ عليهم السلام ជួយអ្នកណាដែលសូមជំនួយពីព្រះអង្គ عليهم السلام ជានិច្ច ថាអ្នកនោះមិនបាច់និយាយកុហកទេ ។

អ៊ីម៉ាំ ហ៊ាសាន់ អាល់-អាស់ការី صلوات الله عليه والسلام បាននិយាយបន្តទៀតថាបុរសនោះគប្បីអរព្រះគុណអល់ឡោះហ៍ عز وجل ដែលព្រះអង្គ عز وجل បានប្រទានអ្វីៗឲ្យគាត់ ។ ចុងក្រោយ អ៊ីម៉ាំ صلوات الله عليه والسلام បានប្រាប់បុរសនោះថាប្រាក់ដែលគាត់បានកប់ទុកនោះ នឹងបាត់ពីកន្លែងលាក់ពេលគាត់ត្រូវការវា ។

បុរសនោះដឹងខ្លួនថាអំពើដែលគាត់បានធ្វើនោះជាអំពើមិនគប្បី ។

ក្រោយមក ពេលបុរសនោះត្រូវការប្រាក់ គាត់ក៏បានទៅជីកដីសួនច្បារយកប្រាក់តែប្រាក់នោះបាត់ពីកន្លែងកប់ ។ កូនប្រុសគាត់បានរកឃើញប្រាក់នោះហើយក៏យកអស់ ។

ដូចអ៊ីម៉ាំ ហ៊ាសាន់ អាល់-អាស់ការី صلوات الله عليه والسلام បានថាមិនខុសមែន ពេលគាត់ត្រូវការប្រាក់គាត់ប្រាក់នោះបាត់ពីកន្លែងដែលគាត់បានលាក់វាទុក ។

ឧត្ដមគតិរឿងនេះគឺ៖

១) អ្នកត្រូវទុកចិត្តលើអល់ឡោះហ៍ عز وجل ដែលមើលថែរក្សាអ្នក ។

២) អ្នកត្រូវអរព្រះគុណអល់ឡោះហ្វ៍﷿ដែលព្រះអង្គ﷿ប្រទានអ្វីៗឲ្យអ្នក ។

៣) អ្នកមិនត្រូវនិយាយកុហកជាដាច់ខាត  ព្រោះមិនយូរមិនឆាប់គេនឹងដឹងការពិត ។ ទោះបីពុំមានអ្នកណាដឹងក៏ដោយ តែអល់ឡោះហ្វ៍﷿ដឹង ។

**លំហាត់ ១៥ក**

# អ៊ីម៉ាំ ហ្ញាសាន់ អាល់-អាស្ការី صلوات الله عليه والسلام

អ៊ីម៉ាំ ហ្ញាសាន់ អាល់-អាស្ការី صلوات الله عليه والسلام ប្រសូតនៅឯម៉ាឌីណាស្ញ ថ្ងៃទី ១០ ខែ រ៉ាប៊ីអ៊ុល អាខៀរ ឆ្នាំ ២៣២ សកករាជហ៊ីជ្រ៉ោះត៏ ត្រូវនិងថ្ងៃទី ០៦/១២/៨៤៦ នៃគ្រិស្តសករាជ ។ ព្រះអង្គ صلوات الله عليه والسلام សោយទិវង្គតនៅឯស្រុកសាម៉ារ៉ា (ប្រទេសអ៊ីរ៉ាក់) ថ្ងៃទី ៨ ខែ រ៉ាប៊ីអ៊ុល អាវ៉ាល់ ឆ្នាំ ២៦០ សកករាជហ៊ីជ្រ៉ោះត៏ ត្រូវនិងថ្ងៃទី ០៤/០១/៨៧៤ នៃគ្រិស្តសករាជ ។

ព្រះបិតា ៖
អ៊ីម៉ាំ អាលី អាន់-ណាគី صلوات الله عليه والسلام

មាតា ៖
ប៊ីប៊ី ស៊ូឡៃល៍ ឬ សៅសាន
(سليل و سوسن)

**អ៊ីម៉ាំ ហ្ញាសាន់ អាល់-អាស្ការី صلوات الله عليه والسلام**

ព្រះរាជបុត្រ ៖
អ៊ីម៉ាំ មូហាំម៉ាដ អាល់-ម៉ាហ្ទី صلوات الله عليه والسلام

## លំហាត់ ១៥ខ

ចូរនិយាយប្រាប់ឪពុកម្ដាយអ្នកអ្វីដែលអ៊ីម៉ាំ ទី ១១ របស់យើង អ៊ីម៉ាំ ហ៊្កាសាន់ អាល់-អាុស់ការី صلوات الله عليه والسلام ប្រាប់បុរសដែលសូមប្រាក់ពីព្រះអង្គ صلوات الله عليه والسلام ដោយថាគាត់មិនមានប្រាក់ទេនោះ ។



## មេរៀនទី ១៦

# អ៊ីមុាំ មូហុាំម៉ាដ់ អាល់-ម៉ាស្ទ់ឌី صلوات الله عليه والسلام

ចាប់តាំងពីអ៊ីមុាំទី ១២ របស់យើង គឺអ៊ីមុាំ មូហុាំម៉ាដ់ អាល់-ម៉ាស្ទ់ឌី صلوات الله عليه والسلام ប្រសូតមកភ្លាម ព្រះអង្គ صلوات الله عليه والسلام ក្រាបប្រណិប័តន៍ (ស៊ូយ្ជូដ) ភ្លាម ។

ក្រោយពីបានប្រសូតមកភ្លាម ស្រីបម្រើបានទៅមើលអ៊ីមុាំ មូហុាំម៉ាដ់ អាល់-ម៉ាស្ទ់ឌី صلوات الله عليه والسلام នៅក្នុងគ្រែ ។ ស្រីបម្រើឲ្យសាឡាមអ៊ីមុាំ صلوات الله عليه والسلام អ៊ីមុាំ صلوات الله عليه والسلام ឆ្លើយតបសាឡាមវិញ ។

ស្រីបម្រើភ្ញាក់ផ្អើលជាទីបំផុត ។ បន្ទាប់ពីនោះស្រីបម្រើកណ្ដាស់ អ៊ីមុាំ មូហុាំម៉ាដ់ អាល់-ម៉ាស្ទ់ឌី صلوات الله عليه والسلام បាននិយាយពីក្នុងគ្រែថា៖ "يَرْحَمُكِ اَللهُ យ៉ារហ្ញាមូគីល-ឡាស្ទ់ ។ នេះគឺព្រះពររបស់អល់ឡោះហ្វ៍ عز وجل ។ អ្នកអាចជឿជាក់បានថាអ្នកនឹងមានជីវិតរស់រានបីថ្ងៃខាងមុខ ។"

ឧត្តមគតិរឿងគឺ៖

១) ពេលគេឲ្យសាឡាមមកអ្នក អ្នកត្រូវតែ (វ៉ាយ៉ិប) ឆ្លើយតបសាឡាមគេវិញ អ្នកត្រូវព្យាយាមឆ្លើយតបវិញឲ្យបានច្រើនជាងគេថាមកអ្នក ។

២) ពេលគេកណ្ដាស់ អ្នកត្រូវថាយ៉ារហ្ញាមូកាល់-ឡាស្ទ់ (ឬ បើអ្នកនោះជាស្រីឲ្យថា យ៉ារហ្ញាមូគីល-ឡាស្ទ់) ។ ពេលអ្នកកណ្ដាស់ខ្លួនឯង អ្នកត្រូវថា អាល់-ហ៊ាំឌូលិលឡាស្ទ់ ។

**លំហាត់ ១៦**ក

# អ៊ីម៉ាំ មូហាំម៉ាដ់ អាល់-ម៉ាស្ទ់ឌី صلوات الله عليه والسلام

អ៊ីម៉ាំ មូហ៊ាំម៉ាដ់ អាល់-ម៉ាស្ទ់ឌី صلوات الله عليه والسلام ប្រសូតនៅឯស្រុកសាម៉ាររ៉អ៍ (ប្រទេសអ៊ីរ៉ាក់) ថ្ងៃទី ១៥ ខែ ស្ហាក់បាន ឆ្នាំ ២៥៥ សករាជហ៊ីជ្ជរ៉ោះត៍ ត្រូវនឹងថ្ងៃទី ២៩/០៧/៨៦៩ នៃគ្រិស្តសករាជ ។ ព្រះអង្គ صلوات الله عليه والسلام គង់ព្រះជន្មនៅឡើយ (សព្វថ្ងៃនេះព្រះអង្គ صلوات الله عليه والسلام មានព្រះជន្មាយុ ១១៥០ ឆ្នាំ) ។

ព្រះបិតា ៖
អ៊ីម៉ាំ ហ៊ាសាន់ អាល់-អាស់ការី صلوات الله عليه والسلام

មាតា ៖
ប៊ីប៊ី ណារយ៉ើស (نرجس)

អ៊ីម៉ាំ មូហ៊ាំម៉ាដ់ អាល់-ម៉ាស្ទ់ឌី صلوات الله عليه والسلام

## លំហាត់ ១៦ខ

ពេលគ្នំលិបឲ្យសាឡាមអ្នក តើអ្នកត្រូវថាអ្វី ?




តើអ្នកត្រូវថាអ្វីពេលអ្នកកណ្តាស់ ? ពេលអ្នកដទៃកណ្តាស់ ?

